**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

១. **ថ្ងៃ ខែ ឆ្នាំ ៖** ថ្ងៃចន្ទ ១២កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦

២. **ទីកន្លែង ៖** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធនិម្មិត(Zoom)។

៣. **ប្រធាន និងសមាសភាពចូលរួម ៖**

៣-១- ប្រធានអង្គប្រជុំ ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងចំងឺអេដស៍។

៣-២- សមាសភាពចូលរួមមាន សមាជិកក្រុមការងារអន្តរក្រសួងតាមដានគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍របស់រាជរដ្ឋាភិបាល និងសមាជិកក្រុមការងារបច្ចេកទេសនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មកពីបណ្ដាក្រសួង ស្ថាប័ន រាជធានី ខេត្តចំនួន៤០រូប និងតាមប្រព័ន្ធនិម្មិត(Zoom) ចំនួន៣៤គណនី។

៤. **របៀបវារៈ៖**

៤.១. សុន្ទរកថាបើកកិច្ចប្រជុំដោយ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៤.២. របាយការណ៍ស្ដីពីលទ្ធផលនៃការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ក្នុងត្រីមាសទី១ ឆ្នាំ២០២៦ ដោយឯក**ឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ ប្រធានក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាសមាជិកក្រុមការងារអន្តរក្រសួងតាមដានគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។

៤.៣. ការលើកម្ពស់មគ្គុទេសភាព នៃការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ដោយឯក**ឧត្តមវេជ្ជបណ្ឌិត ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងប្រធានក្រុមការងារអន្តរក្រសួងតាមដានគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។

៤.៤. កិច្ចពិភាក្សាពេញអង្គដឹកនាំដោយ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៥.៥. សុន្ទរកថាបិទកិច្ចប្រជុំដោយ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. សកម្មភាព និងលទ្ធផល ៖**

នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦ នៅបន្ទប់ប្រជុំ «ខ» នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានកិច្ចប្រជុំក្រុមការងារអន្តរក្រសួងតាមដានគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** ដោយមានការចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិកក្រុមការងារអន្តរក្រសួងតាមដានគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍របស់រាជរដ្ឋាភិបាល និងសមាជិកក្រុមការងារបច្ចេកទេសនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មកពីបណ្តាក្រសួង ស្ថាប័ន រាជធានី ខេត្ត។

កិច្ចប្រជុំនេះ មានគោលបំណង៖

១- ពិនិត្យនូវវឌ្ឍនភាព និងបញ្ហាប្រឈម នៃការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។

២- ជំរុញសកម្មភាពអន្តរវិស័យឆ្លើយតបនឹងមេរោគអេដស៍របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត។

៣- យន្តការច្នៃប្រឌិតក្នុងការកៀគរធនធាន និងការប្រើប្រាស់ថវិកាឱ្យចំគោលដៅ។

៤- ជំរុញការអនុវត្តនូវលិខិតលេខ២១ សជណ.កប ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦ របស់ទីស្តីការរដ្ឋមន្ត្រី។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានថ្លែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅដល់អង្គប្រជុំ ដោយបញ្ជាក់ពីការប្តេជ្ញាចិត្តខ្ពស់ក្នុងស្មារតីទទួលខុសត្រូវរួមគ្នាក្នុងការអនុវត្ត ដើម្បីឈានទៅសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រជាតិដែលរាជរដ្ឋាភិបាលបានដាក់ចេញ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានលើកឡើងពីសមិទ្ធផលដែលបានសម្រេចជោគជ័យនៃការឆ្លើយតបនឹងមេរោគអេដស៍កន្លងមក ដែលធ្វើឱ្យអត្រាផ្ទុកមេរោគអេដស៍នៅកម្ពុជាបានធ្លាក់ចុះជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំមកនៅត្រឹម 0.5% (ឆ្នាំ២០២៤)។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានបញ្ជាក់ពីបញ្ហាប្រឈមមួយចំនួនផង ដែលយោងលទ្ធផលឆ្នាំ២០២៤កន្លងមក ការឆ្លងថ្មីមេរោគអេដស៍នៅកម្ពុជាបានធ្លាក់មកនៅត្រឹមចំនួន ១ ២០០ករណី ប៉ុន្តែនៅឆ្ងាយពីគោលដៅយុទ្ធសាស្ត្រជាតិបានកំណត់ ប្រមាណជា២០០ករណីក្នុងមួយឆ្នាំ។ ចំណែកក្រុមប្រជាជនគន្លឹះនៅមានអត្រាផ្ទុកមេរោគអេដស៍ខ្ពស់នៅឡើយបើធៀបជាមួយប្រជាជនលទូទៅ។

ជាបន្ត**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានអនុញ្ញាតិជូន ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត អគ្គលេខាធិការ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស រាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨(មានភ្ជាប់ជូនជាមួយ)។

ជាបន្តទៀត**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានអនុញ្ញាតជូន ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ស្តីពីការលើកម្ពស់មគ្គុទេសភាព នៃការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ (មានភ្ជាប់ជូនជាមួយ)។

បន្ទាប់មក**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានអនុញ្ញាតឱ្យមានកិច្ចពិភាក្សាយ៉ាងផុសផុល ដោយសមាជិកបានលើកឡើងពីសមិទ្ធផល និងបញ្ហាប្រឈម នៃការអនុវត្តការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍តាមវិស័យនានា ព្រមទទួលបានមតិយោបល់ពីសមាជិកអង្គប្រជុំដូចខាងក្រោម៖

- ស្នើសុំឱ្យមានតំណាងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចូលរួមជាមួយអនុគណៈកម្មាធិការរបស់ក្រសួងទេសចរណ៍ ដើម្បីទទួលព័ត៌មានរៀបចំផែនការផ្សព្វផ្សាយបង្ការទប់ស្កាត់មេរោគអេដស៍តាមស្តង់ VIP និងស្តង់សម្រាប់សាធារណជនជាពិសេសកម្មវិធីប្រគុំតន្ត្រីក្នុងទិវាបុណ្យទន្លេ និងទិវាបុណ្យសមុទ្រ។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រៀបចំលិខិតជូនដំណឹងទៅគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តកណ្តាលករណីប្រជាការពារភូមិឆែក និងដកហូតយកស្រោមអនាម័យពីក្រុមប្រឈមនៅម្តុំភ្នំប្រសិទ្ធ(រាយការណ៍ដោយតំណាងក្រុមប្រឈម ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦ក្នុងកិច្ចប្រជុំអន្តរក្រសួង និងក្រុមប្រឹក្សាបច្ចេកទេស)។
- ក្រុមប្រឈមនៅតែទទួលបានព័ត៌មានតិចតួចពីវិធីបង្ការមេរោគអេដស៍(នៅតែមានក្រុមប្រឈមមិនទទួលយកស្រោមអនាម័យ និងមានជំងឺកាមរោគ សិរមាន់តាមរន្ធគូថ..។ល។) និងក្រុមប្រឈមនៅតែជួបការខ្វះខាតស្រោមអនាម័យ និងទឹករំអិល បើទោះជាមានការជួយឧបត្ថម្ភពីអង្គការPSI ក៏ដោយ។
- លោកស្រី ប៉ាត្រីស្យា អង់ពីន នាយិកាUNAIDS ប្រចាំប្រទេសកម្ពុជា ឡាវ និងមីយ៉ាមា ស្នើសុំឱ្យផ្តល់ជូននូវគម្រូនៃចូលរួមជាបដិភាគរបស់រាជរដ្ឋាភិបាលប្រទេសកម្ពុជា អំពីកិច្ចសន្យាសង្គម(ភ្នាក់ងារអនុវត្តដែលមិនមែនជារដ្ឋ Non State Actors)ឬ ការចូលរួមជាបដិភាគរបស់ផ្នែកឯកជន ឬសប្បុរសជន ដូចជាគម្រូនៃប្រមូលជន(Fund Raising) ដែលរៀបចំធ្វើដោយកាកបាទក្រហមកម្ពុជា។

រៀបចំឱ្យមានអភិបាលកិច្ច និងជំរុញការអនុវត្តលិខិតលេខ២១ ស.ជ.ណ.ក.ប ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦ ស្តីពីករណីវិធានការជំរុញប្រសិទ្ធភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ តាមគ្រឹះស្ថានកម្សាន្តសប្បាយជាមួយ ក្រសួងទេសចរណ៍ ក្រសួងសេដ្ឋកិច្ច ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ និងទីស្តីការគណៈរដ្ឋមន្ត្រី។

បន្ទាប់មក **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍ ជំរុញសមាជិកអង្គប្រជុំឱ្យអនុវត្ត លិខិតលេខ ២១ សជណ.កប ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីដាក់ចេញជាវិធានការដាច់ខាត ជំរុញឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិនៃឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ ដោយផ្តល់អនុសាសន៍អាទិភាពមួយចំនួន ដូចខាងក្រោម៖

- ជំរុញការអនុវត្តនូវសារាចរអន្តរក្រសួងលេខ ០០៧ សហវ.អហក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ ដែលផ្តល់លទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចចាត់ចែង និងប្រើប្រាស់ថវិកាសេវា ដើម្បីឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- ពន្លឿនសេវាបង្ការ និងកិច្ចគាំពារសង្គមសម្រាប់ប្រជាជនគន្លឹះដោយត្រូវបន្តសហការយ៉ាងស្អិតល្មួតជាមួយគណៈអភិបាលរាជធានីខេត្ត ដើម្បីជំរុញ និងលើកទឹកចិត្តក្រុមប្រជាជនគន្លឹះ និងពន្លឿនយន្តការចុះបញ្ជីផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល ដល់ក្រុមគោលដៅទាំងនេះឱ្យបានឆាប់រហ័ស និងទូលំទូលាយបំផុត ដើម្បីធានាបាននូវកិច្ចគាំពារសង្គម និងសេវាសុខាភិបាលប្រកបដោយសមធម៌ និងបរិយាបន្ន។
- បង្កើនការអង្កេត និងការឆ្លើយតបទៅនឹងឥរិយាបថប្រឈមថ្មីៗ ដោយត្រូវបង្កើនការអង្កេតតាមដានយ៉ាងយកចិត្តទុកដាក់លើនិន្នាការ និងឥរិយាបថប្រឈមថ្មីៗ ជាពិសេសតាមរយៈវិធីសាស្ត្រចម្រុះ។
- ជំរុញយុទ្ធសាស្ត្រប្រើប្រាស់ស្រោមអនាម័យ ១០០% ដោយបន្តផ្សព្វផ្សាយ និងរិតបន្តឹងការអនុវត្តសារាចរលេខ ២០ សរ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥ របស់រាជរដ្ឋាភិបាល ស្តីពីការជំរុញការប្រើប្រាស់ស្រោមអនាម័យឱ្យបាន ១០០ភាគរយ។

ចុងបញ្ចប់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានប្រសិទ្ធពរជ័យ សិរិសួស្តី ជ័យមង្គលមហាប្រសើរ ជូនដល់សមាជិកអង្គប្រជុំ មានសុខភាពល្អបរិបូរណ៍ សេចក្តីសុខ សេចក្តីចម្រើន និងសម្រេចបានជោគជ័យថ្មីៗ បន្ថែមទៀត ក្នុងគោលដៅបញ្ចប់អេដស៍ និងធានានិរន្តរភាពកម្មវិធីសម្រាប់ឆ្នាំបន្តបន្ទាប់។

កិច្ចប្រជុំបានបញ្ចប់នៅថ្ងៃខែឆ្នាំដដែល វេលាម៉ោង ១១: ៣០ ប្រកបដោយការទទួលខុសត្រូវខ្ពស់។

ថ្ងៃសុក្រ ១រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៦

អ្នកធ្វើរបាយការណ៍

ស៊ុំ ផល្លា

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

វេជ្ជ. ហួត សេរីរដ្ឋ

បានឃើញ និងឯកភាព
អគ្គលេខាធិការ

បណ្ឌិត ឈឹម យិនដារ៉េត